# សហគមន៍ភូមិគោកដូងអភិរក្សមេពូជត្រីនៅស្ទឹងភាស

ឯកភ្នំ -បាត់ដំបង៖ សហគមន៍ភូមិគោកដូង ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបងស្ថិតនៅខាងជើងទីរួមខេត្តបាត់ដំបងចម្ងាយប្រមាណ១០គីឡូម៉ែត្រ និងហួសពីប្រាសាទឯកភ្នំប្រមាណជាង១គីឡូម៉ែត្រ ដោយធ្វើដំណើរតាមផ្លូវក្រហម ដែលលោកឧកញ៉ាស្វេងណាំ ពីណាងពត្រ្តមណ្ឌលសៀមរាបគ្រោងជួយធ្វើផ្លូវក្រាលកៅស៊ូជំនួសវិញ ចាប់ពីផ្សារដូនទាវរហូតដល់រមណីយដ្ឋានប្រវត្តិសាស្ត្រប្រាសាទឯកភ្នំ ។ ប្រជាជនឆ្លងកាត់និងភ្ញៀវទេសចរអាចធ្វើដំណើរទៅទស្សនាប្រាសាទឯកភ្នំនិងបង្ហួសទៅមើលសហគមន៍គោកដូងដែលអភិរក្សមេត្រីពូជនៅស្ទឹងភាសដោយងាយស្រួល ។

លោកគ្រឿង ហ៊ាន មេភូមិគោកដូង បានឱ្យដឹងថា ភូមិគោកដូងមានប្រជាជនរស់នៅជាង២៥០គ្រួសារ មនុស្សរាយជិត១.០០០នាក់ ។ ក្នុងគ្រួសារនីមួយៗមានផ្ទៃដីស្រែពី៣ទៅ៥ហិកតា ។ ប្រជាជនភូមិគោកដូងមានមុខរបរធ្វើស្រែនិងនេសាទត្រី ។ ក្រៅពីនេះមានដាំបន្លែបង្ការនៅសងខាងស្ទឹងភាសដែលជាតំបន់អភិរក្សមេពូជត្រីដែលសហគមន៍គោកដូងជាអ្នកមើលការខុសត្រូវការពារឱ្យបានគង់វង្សដោយមានការជួយឧបត្ថម្ភពីអង្គការ UNDP អង្គការអភិវឌ្ឍន៍ស្ត្រី...។ល។

លោកប៊ុច សឿន ប្រធានសហគមន៍គោកដូងមានប្រសាសន៍ថា សហគមន៍ទើបតែកើតឡើងបានជាងមួយឆ្នាំ ដោយជ្រើសរើសយកស្ទឹងភាសធ្វើជាកន្លែងអភិរក្សមេពូជត្រី ពីព្រោះទឹកស្ទឹងនេះមិនដែលរីងទេ ទោះបីជាខែប្រាំងក៏ដោយ ។ ទឹកស្ទឹងភាសមានព្រំប្រទល់ជាប់ជាមួយបឹងព្រៃទទឹង ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង។ ស្ទឹងភាសមានបណ្ដោយ១៧០ម៉ែត្រ-ទទឹង៧០ម៉ែត្រ ជម្រៅ៤ទៅ៥ម៉ែត្រនៅរដូវវស្សា ហើយរដូវប្រាំងមានជម្រៅទឹកពី២ទៅ៣ម៉ែត្រ ។

លោកប្រធានសហគមន៍បានបញ្ជាក់ថា គោលបំណងនៃការអភិរក្សមេពូជត្រីនៅតំបន់ស្ទឹងភាសនេះ គឺដើម្បីការពារកុំឱ្យប្រជាជនឬក៏ជនខិលខូចចូលមកនេសាទត្រីនៅក្នុងតំបន់អភិរក្សនេះ ។ បើក្រៅពីតំបន់នេះអាចនេសាទបានមិនមានការហាមឃាត់ទេ។ នៅរដូវវស្សាត្រីនៅតំបន់អភិរក្សនេះអាចចរាចរចេញទៅកាន់ទីវាលសម្រាប់ឱ្យប្រជាជននេសាទជាលក្ខណៈគ្រួសារ ដើម្បីធ្វើជាម្ហូបផងនិងលក់ផងក្រៅពីទុកហូប ។

លោកលឿម លឿ អនុប្រធានសហគមន៍និងជាអ្នកដើរល្បាតការពារតំបន់អភិរក្សស្ទឹងភាសបានបញ្ជាក់ថា ក្រោយពីសហគមន៍ធ្វើការអភិរក្សដោយមានការជួយឧបត្ថម្ភពីអង្គការនានារួចមក ពូជត្រីមានការកើនឡើងមានដូចជាមេត្រីរ៉ស់ ត្រីឆ្តោ ត្រីឆ្ពិន ត្រីក្រាយ ត្រីសណ្ដាយ ត្រីស ត្រីខ្ជួញ...។ល។

លោកលឿម លឿ បានបញ្ជាក់ថា ក្រៅពីជួយសហគមន៍គោកដូង អង្គការUNDP នៅបានជួយសហគមន៍ពីរកន្លែងទៀតស្ថិតនៅស្រុកឯកភ្នំដែរ មានសហគមន៍ព្រែកក្ដោ បឹងវត្តកូនស្ថិតនៅក្នុងភូមិពាមឯក ឃុំពាមឯក និងសហគមន៍របោលស្នួលស្ថិតក្នុងភូមិរបោលស្នួល ឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។ នៅសហគមន៍ ទាំង៣ភូមិនេះអង្គការ UNDP បានជួយថវិកា៣២.៧៣៧ដុល្លារដោយមានការស្ដារបឹងចាស់ពីរកន្លែងនិងដាំព្រៃលិចទឹកឡើងវិញ ។

លោកហុង ហ៊ី ប្រធានការិយាល័យជលផលខេត្តមានប្រសាសន៍ថា ការិយាល័យជំនាញរបស់លោកបានសហការជួយសហគមន៍គោកដូងនិងសហគមន៍២ភូមិទៀតដោយផ្ដល់បច្ចេកទេសធ្វើលូធំៗ ហើយដឹកយកទោទម្លាក់ក្នុងតំបន់អភិរក្សត្រីមេពូជនេះដើម្បីធ្វើជាជម្រកឱ្យត្រីចូលពងកូនធ្វើឱ្យចំនួនត្រីកាន់តែកើនឡើង ។ ត្រីអភិរក្សទាំងនេះពេលរដូវវស្សាទឹកជំនន់ឡើងពាសវាលពាសកាល វាបានផ្លាស់ទីចេញពីតំបន់អភិរក្សនេះទៅកន្លែងផ្សេងៗ ដែលប្រជាជនអាចនេសាទត្រីទាំងនេះជាលក្ខណៈគ្រួសារបានតាមសេចក្ដីត្រូវការ ៕

ក្រញូង



ស្ទឹងភាស តំបន់អភិរក្សមេត្រីពូជសហគមន៍គោកដូង មិនចេះរីងស្ងួតទេ (រូបថត:ក្រញូង)